# មហាអនុតំបន់ទន្លេមេគង្គ
# កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA)
# ការបើកដំណើរការឡើងវិញឆ្នាំ ២០២៤
# «ដំណាក់កាលប្រមូលផលដំហានដំបូង ( EARLY HARVEST )»

# មេរៀនទី ៤ - ការប្រើប្រាស់ប័ណ្ណចុះបញ្ជី

បង្កើតឡើងក្រោមគម្រោងជំនួយបច្ចេកទេសលេខ TA 6579-REG ៖ ការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន «ដំណាក់កាលប្រមូលផលដំហានដំបូង» ក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមរយៈសហហិរញ្ញប្បទាន ដោយ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស

- ផ្អែកទៅលើអនុស្សារណៈយោគយល់នៃCBTA 'Early Harvest' ប្រទេសសមាជិកមហាអនុតំបន់ទន្លេមេគង្គនីមួយៗ អាចផ្តល់ឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs)សម្រាប់យានយន្ត (ដឹកទំនិញ និង អ្នកដំណើរ) រហូតដល់ ៥០០ ដែលជាកម្មសិទ្ធិ និង ធ្វើប្រតិបត្តិការដោយប្រតិបត្តិករដឹកជញ្ជូនដែលមានលិខិតអនុញ្ញាតិនៅក្នុងប្រទេសពួកគេ។
- លិខិតអនុញ្ញាត (Permit) និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន(TAD)នីមួយៗមានលេខយោងរៀងៗខ្លួន (សូមមើលបន្ថែម នៅម៉ូឌុល អំពី ការផ្តល់លិខិតអនុញ្ញាត និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន។
- លេខយោងទាំងនេះ និងលក្ខណៈសម្គាល់ដាច់ដោយឡែកផ្សេងៗទៀត ត្រូវតែមានកត់ត្រាក្នុងបញ្ជីក្រៅផ្លូវការ ឬ**បញ្ជីនៃលិខិតអនុញ្ញាត និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន** (ក្នុងទម្រង់ជាឯកសារ Excel ដែលផ្តល់អោយដោយប្រទេសមាជិកទាំងអស់) ស្របតាមមាត្រា ៤ នៃអនុស្សារណៈយោគយល់នៃ 'Early Harvest'។

- យោងតាមមាត្រា ៤ ប្រទេសសមាជិកត្រូវតែ **រាយការណ៍អំពីបច្ចុប្បន្នភាពនៃការចុះបញ្ជីចុះឈ្មោះថ្នាក់ជាតិ** នៃប្រតិបត្តិករដឹកជញ្ជូនផ្លូវគោកដែលមានអញ្ញាប័ណ្ណលិខិតអនុញ្ញាត និងឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ននៅរយៈពេល២សប្តាហ៍ មុនពេលត្រីមាសនីមួយៗ( ឧ.ជារៀងរាល់៣ខែ ចាប់ផ្តើមពី ថ្ងៃ១៥ មីនា ២០២៤ )នៅក្នុង កិច្ចប្រជុំគណៈកម្មាធិការចម្រុះ។
- ការរាយការណ៍ អាចធ្វើតាមរយៈ ADB ( តាមអ៊ីមែល ) សម្រាប់ការបញ្ជាក់ និងការផ្សព្វផ្សាយបន្តទៅកាន់សមាជិកផ្សេងៗ
- បញ្ជីចុះឈ្មោះ នឹងត្រូវធ្វើការពិនិត្យជារៀងរាល់ឆ្នាំ និងកែសម្រួលតាមភាពជាក់ស្តែងសមស្របតាម មាត្រា ២ និងមាត្រា ៥ នៃពិធីការ ៣។

- **អាជ្ញាធរជាតិមានសិទ្ធផ្តល់លិខិតអនុញ្ញាត (Permit) ដឹកជញ្ជូនតាមផ្លូវ GMS នៅតាមប្រទេសនីមួយៗ មានដូចជា:**
  - ព្រះរាជាណាចក្រកម្ពុជា
    **គណៈកម្មការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់**
  - សាធារណរដ្ឋប្រជាមានិតចិន
    **ក្រសួងដឹកជញ្ជូនចិន**
  - សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
    **នាយកដ្ឋានដឹកជញ្ជូន**
  - សាធារណរដ្ឋនៃសហភាពមីយ៉ាន់ម៉ា
    **គណៈកម្មការជាតិសម្របសម្រួលការដឹកជញ្ជូន**
  - ព្រះរាជាណាចក្រថៃ
    **នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**
  - សាធារណរដ្ឋសង្គមនិយមវៀតណាម
    **នាយកដ្ឋានផ្លូវថ្នល់នៃប្រទេសវៀតណាម**



- អាជ្ញាធរជាតិមានសិទ្ធផ្តល់ឯកសារអនុញ្ញាតឱ្យយានយន្តចូលបណ្តោះអាសន្ន (TAD) ដឹកជញ្ជូនតាមផ្លូវ GMS នៅតាមប្រទេសនីមួយៗ មានដូចជា:
  - ព្រះរាជាណាចក្រកម្ពុជា
    **គណៈកម្មការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់**
  - សាធារណរដ្ឋប្រជាមានិតចិន
    **សមាគមដឹកជញ្ជូនផ្លូវថ្នល់ចិន**
  - សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
    **នាយកដ្ឋានដឹកជញ្ជូន**
  - សាធារណរដ្ឋនៃសហភាពមីយ៉ាន់ម៉ា
    **នាយកដ្ឋានគយនៃប្រទេសមីយ៉ាន់ម៉ា**
  - ព្រះរាជាណាចក្រថៃ
    **នាយកដ្ឋានគយ**
  - សាធារណរដ្ឋសង្គមនិយមវៀតណាម
    **ក្រសួងដឹកជញ្ជូននៃប្រទេសវៀតណាម**



- ទម្រង់ចុះបញ្ជី នៃការចាប់ផ្តើមប្រតិបត្តិការ ‛Early Harvest′ ត្រូវបានអនុម័តអោយប្រើប្រាស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី៥
- ទម្រង់ មានលក្ខណៈជា Excel Workbook និង**ត្រូវបំពេញជាភាសាអង់គ្លេស**
- ទោះជាយ៉ាងណាក៏ដោយ ប្រទេសនីមួយៗ បញ្ចូលភាសាជាតិបន្ថែម អមភាសាអង់គ្លេស
- ការប្រើប្រាស់ភាសាជាតិ **គួរតែប្រើអមភាសាអង់គ្លេស និងរក្សាភាសាអង់គ្លេសនៅដដែល** (ដោយសារតែការបកប្រែអាចលម្អៀង ឬមិនត្រូវន័យដើមទាំងស្រុង)

- បញ្ជីចុះឈ្មោះចាប់ផ្តើមជាមួយ កូឡុំ A ដល់ AJ ។. សរុប ៣៦ កូឡុំ
- ប្រសិនបើ Permits and TADs ចំនួន៥០០ ត្រូវបានផ្តល់ ដូច្នេះនឹងមានបន្ទាត់ ជាភាសាអង់គ្លេសចំនួណ៥០០ និងភាសាជាតិចំនួន ៥០០
- ទម្រង់ចុះបញ្ជី សង្ខេប មានរូបរាងដូចខាងក្រោម៖
  - កូឡុំ ពណ៌លឿង (B ទៅ G) កត់ត្រាពី ព័ត៌មានលម្អិតនៃលិខិតអនុញ្ញាតិ (Permit)
  - កូឡុំ ពណ៌ប្រផេះ (A ទៅ H) កត់ត្រា ភាសា និង លេខ TAD
  - កូឡុំ ពណ៌ខៀវ (I ទៅ R) កត់ត្រាព័ត៌មានលម្អិត ម្ចាស់យានយន្ត ឬប្រតិបត្តិករដឹកជញ្ជូន
  - កូឡុំ ពណ៌ទឹកក្រូច (S ទៅ AJ) កត់ត្រាព័ត៌មានលម្អិតរបស់យានយន្ត
- **ព័ត៌មានលម្អិតផ្សេងៗដែលបានកត់ត្រាក្នុង បញ្ជីចុះឈ្មោះ ត្រូវតែដូចគ្នាទៅនឹងព័ត៌មានលើ Permits និង TADs**

| | A | B | G | H | I | J | Q | R | S | T | U | AH | AI | AJ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Language | Permit Number | Issuing Authority | Motor Vehicle TAD Number | Name of Transport Operator | Address | Telephone | E-mail | Type of Vehicle | Registration Number | Vehicle Category | Width in Metres | Length in Metres | Height in Metres |
| 2 | English | PER-GMS/LAO-0001 | | TAD-GMS/LAO-0001 | | | | | | | | | | |
| 3 | | | | | | | | | | | | | | |
| 4 | National | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | |
| 6 | English | PER-GMS/LAO-0002 | | TAD-GMS/LAO-0002 | | | | | | | | | | |
| 7 | | | | | | | | | | | | | | |
| 8 | National | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | |

- លេខ TAD ត្រូវស្របតាមទម្រង់ដែលបានព្រមព្រៀងគ្នារវាងភាគីចុះកិច្ចសន្យា។ ដោយយកតាមលំនាំពាក្យ 'TAD-GMS/' លេខកូដប្រទេសដែលជាសម្គាល់ដោយឡែកនៃយានយន្តរបស់ប្រទេសនោះ: កម្ពុជា: KH សាធារណរដ្ឋប្រជាមានិតចិន: CHN សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ: LAO មីយ៉ាន់ម៉ា: MYA ថៃ: T និងវៀតណាម: VN
- TADs គួរមានចន្លោះលេខពី 0001 និង 0500 ពោលគឺ TAD-GMS/KH-0001 ឬ TAD-GMS/VN-0500 ( ដូចគំរូ TAD ដំបូងសម្រាប់ប្រទេសកម្ពុជា និង TAD ចុងក្រោយសម្រាប់ប្រទេសវៀតណាម )

| Language | Permit Number | Issue Date | Place of Issue | Expiry Date (Valid Until) | Extended Until | Issuing Authority | Motor Vehicle TAD Number |
|---|---|---|---|---|---|---|---|
| English | PER-GMS/LAO-0001 | | | | | | TAD-GMS/LAO-0001 |
| | | | | | | | |
| National | | | | | | | |
| | | | | | | | |
| English | PER-GMS/LAO-0002 | | | | | | TAD-GMS/LAO-0002 |
| | | | | | | | |
| National | | | | | | | |
| | | | | | | | |

| H | I | J | K | L | M | N |
|---|---|---|---|---|---|---|
| Motor Vehicle TAD Number | Name of Transport Operator | Address | Province | Telephone | E-mail | Name of Vehicle Owner (If different from Operator) |
| TAD-GMS/LAO-0001 | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| TAD-GMS/LAO-0002 | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

- ការចុះបញ្ជី Permits និង TADs តាមប្រទេសនីមួយៗ ត្រូវតែមានការកត់ត្រាទុក ព័ត៌មានលម្អិត នៃ ប្រតិបត្តិករដឹកជញ្ជូន និង ម្ចាស់យានយន្ត និងព័ត៌មានយានយន្តសំខាន់ៗផ្សេងទៀត

| S | T | U | V | W | X | Y | Z |
|---|---|---|---|---|---|---|---|
| Type of Vehicle | Registration Number | Vehicle Category | Date of Registration | Registered at Province | Brand | Model | VIN Number |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

- ចន្លោះបំពេញព័ត៌មានលម្អិតទាំងស្រុង មាននៅស្លាយបន្ទាប់

- កូឡុំ ពណ៌លឿង (B ទៅ G) កត់ត្រាពី ព័ត៌មានលម្អិតនៃលិខិតអនុញ្ញាតិ (Permit)
  - ✓ លេខ Permit
  - ✓ កាលបរិច្ឆេទចេញលិខិត
  - ✓ ទីកន្លែងចេញលិខិត
  - ✓ កាលបរិច្ឆេទផុតកំណត់ (មានសុពលភាពរហូតដល់)
  - ✓ ពន្យាររហូតដល់
  - ✓ អាជ្ញាធរចេញលិខិត

- កូឡុំ ពណ៌ប្រផេះ (A ទៅ H) កត់ត្រា ភាសា និង លេខ TAD
  - ✓ ភាសា
  - ✓ លេខ TAD នៃយានយន្ត

- កូឡុំ ពណ៌ខៀវ (I ទៅ R) កត់ត្រាព័ត៌មានលម្អិត ម្ចាស់យានយន្ត ឬប្រតិបត្តិករដឹកជញ្ជូន
  - ✓ ឈ្មោះប្រតិបត្តិករដឹកជញ្ជូន
  - ✓ អាសយដ្ឋាន
  - ✓ ខេត្ត
  - ✓ ទូរស័ព្ទ
  - ✓ អ៊ីមែល
  - ✓ ឈ្មោះម្ចាស់យានយន្ត (ប្រសិនបើខុសពីប្រតិបត្តិករ)
  - ✓ អាសយដ្ឋាន
  - ✓ ខេត្ត
  - ✓ ទូរស័ព្ទ
  - ✓ អ៊ីមែល

- កូឡុំ ពណ៌ទឹកក្រូច (S ទៅ AJ) កត់ត្រព័ត៌មានលម្អិតរបស់យានយន្ត

✓ ភេទយានយន្ត
✓ លេខចុះបញ្ជី
✓ ក្រុម/ថ្នាក់នៃយានយន្តយន្ត
✓ កាលបរិច្ឆេទចុះបញ្ជី
✓ ចុះបញ្ជីនៅខេត្ត
✓ ម៉ាក
✓ ម៉ូដែល
✓ លេខ VIN
✓ លេខម៉ាស៊ីន

✓ ចំនួននៃបន្ទុកអ័ក្ស
✓ ពណ៌ Colour
✓ កម្លាំងម៉ាស៊ីន ជា Cc
✓ ទម្ងន់សរុប ជា គ.ក្រ
✓ ទម្ងន់សុទ្ធ ជា គ.ក្រ
✓ ចំនួនកៅអី (សម្រាប់ឡានក្រុង)
✓ ទទឹង ជា ម៉ែត្រ
✓ បណ្តោយ ជាម៉ែត្រ
✓ កម្ពស់ ជាម៉ែត្រ

- ព័ត៌មានលម្អិតបន្ថែមអំពី CBTA 'Early Harvest' រួមទាំងអត្ថបទនៃ អនុស្សរណៈយោគយល់ 'Early Harvest' ដែលបានចុះហត្ថលេខា ច្បាប់ចម្លងគំរូនៃលិខិតអនុញ្ញាត (Permits) និង ឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) និង ច្បាប់ចម្លងនៃខិត្តប័ណ្ណ 'Early Harvest' មាននៅលើគេហទំព័រ www.greattermekong.org/ttf ។

សូមអរគុណ!

បង្កើតឡើងក្រោមគម្រោងជំនួយបច្ចេកទេសលេខ TA 6579-REG ៖ ការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន «ដំណាក់កាលប្រមូលផលដំបូង» ក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមរយៈសហហិរញ្ញប្បទាន ដោយ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស